**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ១៦៤....បទ.គល

ថ្ងៃ ព្រហ ១៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង
## ស្ដីពីការអញ្ជើញចូលរួមដេញថ្លៃ
## ជួសជុល ផ្លាស់ប្ដូរ និងថែទាំឧបករណ៍បច្ចេកទេសប្រព័ន្ធវីដេអូ
## នៃសន្និសីទរបស់រាជរដ្ឋាភិបាលនៅភូមិគ្រឹះសម្ដេចតេជោវិមានឯករាជ្យ
## វិមានសន្តិភាព ទីស្ដីការគណៈរដ្ឋមន្ត្រី ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការជួសជុល ផ្លាស់ប្ដូរ និងថែទាំឧបករណ៍បច្ចេកទេសប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលនៅភូមិគ្រឹះសម្ដេចតេជោវិមានឯករាជ្យ វិមានសន្តិភាព ទីស្ដីការគណៈរដ្ឋមន្ត្រី ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំសំណើដេញថ្លៃសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..៣១.. ខែ..ឧសភា..ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង១៤:០០សៀល ថ្ងៃទី..៤.....ខែកក្កដា..ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ..១៤:០០... រសៀល ថ្ងៃទី..៤..... ខែកក្កដា. ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រកពតែមួយអាចដាក់ឯកសារដេញថ្លៃ បានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**សារ៉ាត់ ខាន់**

ចម្លងជូន :
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ